ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងសភាស៊ើបសួរ

លេខ:២៣៣ /១៥-០៨-២០១១

សាលដីកា

លេខ:១៣ ក្រ.II /១០-០៤-២០១២

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី១០ខែមេសាឆ្នាំ២០១២ ដោយមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សា**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីសភាស៊ើបសួរលេខ២៣៣ ចុះថ្ងៃទី១៥-០៨-២០១១ រវាង:

<u>ជនត្រូវចោទ:</u>

១/ឈ្មោ[redacted]អង្គារ៉ា ហៅ ពៅ ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង កើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ន[redacted]ណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០៥នាក់ ទោសពីមុនគ្មាន។

មានមេធាវីការពារឈ្មោះ: [redacted] វ៉េងកា

២/ ឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ ដូរ កើតនៅខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នផ្ទះ[redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] មានកូន០៦នាក់ ទោសពីមុនគ្មាន។

មានមេធាវីការពារឈ្មោះ:[redacted]ណ្ណឌី

ត្រូវចោទពីបទៈ ផិត និងបទ អំពើអាសប្រគាំងនឹងអនិតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ឯកពន្ធភាព និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ហៅ ពៅ ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៤AE0 ផ្លូវលេខ១១២ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មានមេធាវីតំណាងឈ្មោះ [redacted] ចំណាន

## ៦រឿងហេតុមានដូចតទៅ

កាលពីឆ្នាំ២០១០ ឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ ៤១ឆ្នាំ និងកូនស្រីឈ្មោះ [redacted] កុសិតា អាយុ ១៥ឆ្នាំ បានធ្វើដំណើរទៅលេងប្រទេសវៀតណាមជាមួយឈ្មោះ [redacted] អង្គារ៉ា ភេទប្រុស អាយុ ៤១ឆ្នាំ។ ពេលទៅដល់ប្រទេសវៀតណាម ឈ្មោះ [redacted] សេងហ៊ួយ និងកូនស្រី រួមជាមួយឈ្មោះ [redacted] អង្គារ៉ា និងអ្នករួមដំណើរផ្សេងទៀត បានស្នាក់នៅក្នុងសណ្ឋាគារ ដោយដេកមួយបន្ទប់រួមគ្នា។ ពេលកំពុងដេកក្នុងបន្ទប់ ឈ្មោះ [redacted] អង្គារ៉ា បានលូកស្ទាបអង្អែលប្រដាប់ភេទជនរងគ្រោះឈ្មោះ [redacted] កុសិតា ដែលដេកគ្រែជាមួយគ្នា ហើយបន្ទាប់មកឈ្មោះ [redacted] សេងហ៊ួយ ជាម្តាយបានអោបថើប និងរួមភេទជាមួយឈ្មោះ [redacted] អង្គារ៉ា នៅចំពោះមុខជនរងគ្រោះ។

នៅក្នុងឆ្នាំ២០១០ ដដែលនោះដែរ ឈ្មោះ [redacted] អង្គារ៉ា បានទៅលេងខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី ជាមួយឈ្មោះ [redacted] សេងហ៊ួយ និងកូនស្រីឈ្មោះ [redacted] កុសិតា ទៀត ហើយពេលនៅខេត្តមណ្ឌលគិរី អ្នកទាំងបីបានដេកបន្ទប់ជាមួយគ្នា ខណៈពេលនោះឈ្មោះ [redacted] សេងហ៊ួយ បានអោបថើបជាមួយឈ្មោះ [redacted] អង្គារ៉ា នៅចំពោះមុខកូនតែម្តង លុះដល់ព្រឹកឡើងពេលនាំគ្នាទៅលេងជ្រោះប៊ូស្រា ឈ្មោះ [redacted] អង្គារ៉ា បានយកម្រាម [redacted]

-បានឃើញ**ដីការលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

**លើកលែងការចោទប្រកាន់លើៈ**

-ឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ ៤១ឆ្នាំ ជាតិខ្មែរ ពីបទ ផិត និងបទ អំពើអាសប្រគាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ឯកពន្ធភាព និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

-ឈ្មោះ[redacted]អង្គារ៉ា ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង ពីបទ **អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ឯកពន្ធភាព និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី១៩-០៩-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

| | |
|---|---|
| -ជនត្រូវចោទឈ្មោះ[redacted]អង្គារ៉ា | (អវត្តមាន) |
| -មេធាវីការពារឈ្មោះ [redacted]វ៉េងកា | (វត្តមាន) |
| -ជនត្រូវចោទឈ្មោះ[redacted]សងហ៊ួយ | (អវត្តមាន) |
| -មេធាវីការពារឈ្មោះ [redacted]វណ្ណឌី | (វត្តមាន) |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ចន្ថា | (អវត្តមាន) |
| -មេធាវីតំណាងឈ្មោះ[redacted]ណាន | (អវត្តមាន) |

-ក្រឡាបញ្ជីអានចម្លើយរបស់ជនត្រូវចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើការសន្និដ្ឋានថា:**

ក្នុងរឿងនេះ សុំចៅក្រមពិចារណា សម្រេចតាមច្បាប់ចុះ។

-លោក[redacted]វ៉េងកា ជាមេធាវីការពារជនត្រូវចោទឈ្មោះ [redacted] អង្គារ៉ា ធ្វើការសន្និដ្ឋានថា: ក្នុងរឿងនេះ សំណូមពរសុំក្រុមប្រឹក្សាសម្រេចតម្កល់ដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣-០៨-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

-លោក[redacted]ណ្ណឌី ជាមេធាវីការពារជនត្រូវចោទឈ្មោះ[redacted]សងហ៊ួយ ធ្វើការសន្និដ្ឋានថា: ក្នុងរឿងនេះ សំណូមពរសុំក្រុមប្រឹក្សាសម្រេចតម្កល់ដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣-០៨-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនត្រូវចោទ និងចម្លើយរបស់ដើមបណ្តឹង។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន

-ក្រោយពីបានស្តាប់មេធាវីការពារជនត្រូវចោទធ្វើការសន្និដ្ឋាន



Scanned with CamScanner

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់។

## សាលាឧទ្ធរណ៍យល់ឃើញថា:

១-បណ្តឹងឧទ្ធរណ៍លេខ ៥៥១ ចុះថ្ងៃទី០៥-០៨-២០១១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ប្តឹងឧទ្ធរណ៍នឹងដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣-០៨-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចលើដីកាសម្រេចទាំងមូល។

-បណ្តឹងឧទ្ធរណ៍លេខ ៥៥២ ចុះថ្ងៃទី ០៥-០៨-២០១១ ឈ្មោះ ពៅ ចន្ថា ប្តឹងឧទ្ធរណ៍ នឹងដីកាលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣-០៨-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ។ បណ្តឹងឧទ្ធរណ៍ទាំងពីរនេះ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះយកមកជំនុំជម្រះបានតាមច្បាប់។

២-តាមលទ្ធផលនៃការស៊ើបសួររបស់សាលាដំបូងរាជធានីភ្នំពេញ ឃើញថាពុំមានភស្តុតាងដាក់បន្ទុកលើជនត្រូវចោទឈ្មោះ [redacted] សេងហ៊ួយ ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ ពីបទ ផិត និងឈ្មោះ [redacted] អង្គារ៉ា ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ សញ្ជាតិបារាំង និងឈ្មោះ [redacted] សងហ៊ួយ ពីបទ អំពើអាសប្រឆាំងអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅប្រទេសវៀតណាម និងខេត្តមណ្ឌលគិរី កាលពីឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

៣-តំណាងមហាអយ្យការធ្វើការសន្និដ្ឋាន សុំឲ្យសភាស៊ើបសួរសម្រេចតាមច្បាប់ចុះ។

៤-ដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍តំកល់ដីកាសម្រេចនេះទុកជាបានការពេញទាំងមូល។

## ហេតុដូច្នេះសម្រេច

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៥១ និង ៥៥២ ចុះថ្ងៃទី០៥-០៨-២០១១ របស់ឈ្មោះ [redacted] ន្ថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។



Scanned with CamScanner

២-តម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៣២២៤ ត.ព្រ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១០-០៤-២០១២ ចំពោះមុខមេធាវីការពារជនត្រូវចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជ្រះ |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner